# បរិយាយប័ណ្ណឱសថ
# ស៊ីប្រូផ្លុកសាស៊ីន ព្យួរតាមសរសៃឈាម

## CIPROFLOXACIN

### I រូបភាពឱសថ :
-ជាឱសថប្រភេទសូលុយស្យុងសំរាប់ចាក់ព្យួរតាមសរសៃឈាម
-១ប្រអប់មាន ១ដបប្លាស្ទិក ចំណុះ 100ml

### II សមាសធាតុផ្សំ : ក្នុង 100ml មាន៖
-Ciprofloxacin…………………...200mg

### III គុណភាពព្យាបាល :
ជាប្រភេទឱសថអង់ទីប៊ីយ៉ូទិកឋិតក្នុងក្រុម quinolone ប្រើសំរាប់ព្យាបាល ជំងឺឆ្លងច្រើនប្រភេទដែលកបនឹងឱសថនេះដូចជា៖

**ចំពោះមនុស្សពេញវ័យ៖**

ជំងឺឆ្លងក្នុងផ្លូវដង្ហើមផ្នែកខាងក្រោមដោយសារបាក់តេរី Gram$^{-}$ ដូចជា៖
-ជំងឺរលាកស្ទួតដកដង្ហើមញាប់ៗ
-ជំងឺឆ្លងក្នុងទងសួត
-ជំងឺអំបៅអំបែកត្រចៀកភ្នំរ៉ែ
ជំងឺរលាកឆ្អឹងរូងច្រមុះស្រួចស្រាវនឹងរ៉ាំរ៉ៃ ជាពិសេសជំងឺឆ្លងដោយសារបាក់តេរី Gram$^{-}$ ដូចជា៖
-ជំងឺឆ្លងក្នុងផ្លូវបន្តពូជនិងផ្លូវបង្ហូរនោម
-ជំងឺប្រមេះមាត់ស្បូន និងប្រមេះទឹកបាយដោយសារមេរោគហ្គូណូកូក
-ជំងឺឆ្លងក្នុងផ្លូវក្រពះពោះវៀន (ជំងឺរាករបស់អ្នកធ្វើដំណើរ)
-ជំងឺឆ្លងផ្ទៃខាងក្នុងពោះ
-ជំងឺរលាកឆ្អឹងត្រគាក
-ជំងឺឆ្លងលើស្បែកនិងជាលិកាទន់
-ជំងឺអំបៅអំបែកត្រចៀកកាចសាហាវ
-ជំងឺឆ្លងក្នុងឆ្អឹងនិងសន្លាក់
-បង្ការការរីករាតត្បាតជំងឺឆ្លងដោយសារមេរោគ Neisseria meningitides
-ព្យាបាលនិងបង្ការកាពុលដោយសារសារធាតុ anthrax
-ឱសថនេះអាចប្រើសំរាប់គ្រប់គ្រងការកើនឡើងចំនួន neutrophils ចំពោះអ្នក ជំងឺគ្រុនក្តៅដែលសង្ស័យថាមានជំងឺឆ្លង

ចំពោះកូនក្មេងនិងមនុស្សវ័យជំទង់៖
-ជំងឺឆ្លងក្នុងទងសួត
-ជំងឺឆ្លងក្នុងផ្លូវបង្ហូរនោមធ្ងន់ធ្ងរ និងជំងឺរលាកផ្លោកនោម
-ព្យាបាលនិងបង្ការការពុលដោយសារសារធាតុ anthrax
-ឱសថនេះអាចប្រើសំរាប់ព្យាបាលជំងឺឆ្លងធ្ងន់ធ្ងរចំពោះកុមារនិងមនុស្ស វ័យជំទង់ប្រសិនបើចាំបាច់
ការព្យាបាលដោយប្រើឱសថនេះត្រូវធ្វើឡើងដោយគ្រូពេទ្យដែលមានបទពិសោធន៍ក្នុង ការព្យាបាលជំងឺឆ្លងធ្ងន់ធ្ងរចំពោះកូនក្មេងនិងមនុស្សវ័យជំទង់តែប៉ុណ្ណោះ។
ឱសថនេះមិនមែនជាឱសថជម្រើសទី១សំរាប់ព្យាបាលជំងឺឆ្លងចំពោះកូនក្មេង ទេដោយសារតែវាធ្វើឲ្យកើតមានប្រតិកម្មរំខាន។

### IV ការហាមប្រើ :
ឱសថនេះហាមប្រើចំពោះលក្ខខណ្ឌដូចខាងក្រោម៖
-ចំពោះអ្នកងាយមានប្រតិកម្មជាមួយនឹង ciprofloxacin ឬជាមួយឱសថផ្សេង ទៀតក្នុងក្រុម quinolone ឬជាមួយសារធាតុផ្សំណាមួយនៃឱសថនេះ។
-ហាមប្រើឱសថនេះរួមបញ្ចូលគ្នាក្នុងពេលតែមួយជាមួយឱសថ tizanidine
-ចំពោះអ្នកជំងឺកូនក្មេងអាយុក្រោម១៨ឆ្នាំ
-ចំពោះស្ត្រីមានផ្ទៃពោះ
-ចំពោះស្ត្រីបំបៅដោះកូន

### V ការប្រុងប្រយ័ត្ន :
ឱសថនេះត្រូវប្រុងប្រយ័ត្នចំពោះលក្ខខណ្ឌដូចខាងក្រោម៖
-ចំពោះអ្នកជំងឺឆ្កួតជ្រូកឬអ្នកធ្លាប់មានប្រវត្តិកើតជំងឺប្រព័ន្ធសរសៃ ប្រសាទកណ្តាល
-ចំពោះអ្នកមានជំងឺខ្លាញ់រុំសរសៃឈាមក្នុងខួរក្បាលធ្ងន់ធ្ងរ
-ចំពោះអ្នកមានជំងឺដាច់សរសៃឈាមក្នុងខួរក្បាល
-ចំពោះអ្នកជំងឺខ្សោយមុខងារថ្លើម ឬមុខងារតំរងនោម
-ចំពោះអ្នកជំងឺចាស់ជរា
-ឱសថនេះមិនត្រូវបានណែនាំឲ្យប្រើជាទូទៅចំពោះកូនក្មេង និងមនុស្សវ័យជំទង់ លើកលែងតែមានផលចំណេញច្រើនជាងហានិភ័យ។
-ការព្យាបាលដោយប្រើឱសថនេះតែមួយមុខមិនមានប្រសិទ្ធភាពសំរាប់ការ ព្យាបាលជំងឺឆ្លងធ្ងន់ធ្ងរដោយសារមេរោគ Gram+ ឬដោយសារមេរោគដែលរស់មិនត្រូវការខ្យល់។ ដូច្នេះឱសថនេះត្រូវប្រើរួមផ្សំជាមួយឱសថ អង់ទីប៊ីយ៉ូទិកផ្សេងទៀត។
-ឱសថនេះមិនណែនាំឲ្យប្រើសំរាប់ការព្យាបាលជំងឺឆ្លងដោយសារមេរោគ Streptococci ទេ ព្រោះវាមិនមានប្រសិទ្ធភាព។
-អ្នកជំងឺដែលព្យាបាលដោយប្រើឱសថនេះត្រូវផឹកទឹកអោយបានច្រើន
-ត្រូវប្រើឱសថនេះដោយប្រុងប្រយ័ត្នចំពោះអ្នកមានជំងឺចង្វាក់បេះដូងដើរខុសប្រក្រតី ( prolong QT interval)
-អ្នកជំងឺដែលប្រើឱសថនេះត្រូវជៀសវាងប៉ះពាល់ផ្ទាល់ជាមួយពន្លឺព្រះអាទិត្យ ឬកាំរស្មី UV
-ឱសថនេះអាចធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពបើកបរនិងបញ្ជាគ្រឿងម៉ាស៊ីន
-មិនត្រូវប្រើឱសថនេះលើសកំរិតណែនាំ
-មិនត្រូវប្រើឱសថនេះហួសកាលបរិច្ឆេទប្រើប្រាស់
-មិនត្រូវប្រើឱសថនេះទេ ប្រសិនបើសូលុយស្យុងក្នុងដបឡើងល្អក់ឬដបធ្លាយ

### VI ផលរំខាន :
ផលរំខានដែលកើតមានមិនសូវញឹកញាប់របស់ឱសថនេះរួមមាន៖
-ជំងឺឆ្លងនិងការរាតត្បាតជំងឺឆ្លង៖ ជំងឺផ្សិត
-វិបត្តិគ្រាប់ឈាមនិងប្រព័ន្ធផលិតគ្រាប់ឈាម៖ កើនឡើងចំនួន eosinophils
-វិបត្តិប្រព័ន្ធស៊ាំសរីរាង្គ៖ ប្រតិកម្មអាល្លែកហ្ស៊ី
-វិបត្តិអាហារូបត្ថម្ភនិងមេតាបូលីស៖ មិនសូវឃ្លាន
-វិបត្តិផ្លូវចិត្ត៖ រវើរវាយ
-វិបត្តិប្រព័ន្ធសរសៃប្រសាទ៖ឈឺក្បាល ធេងធោង គេងមិនលក់ មិនសូវដឹងរសជាតិ
-វិបត្តិចក្ខុ៖ ស្រវាំងភ្នែក
-វិបត្តិត្រចៀកនិងបំពង់សំលេង៖ ហឹងត្រចៀក ស្តាប់មិនសូវលឺ
-វិបត្តិបេះដូង៖ បេះដូងដើរញាប់
-វិបត្តិសរសៃឈាម៖ សរសៃឈាមរីក
-វិបត្តិផ្លូវដង្ហើម៖ ពិបាកដកដង្ហើម
-វិបត្តិក្រពះពោះវៀន៖ ក្អួត ចង្អោរ រាក ហើមពោះ ពិបាករំលាយអាហារ
-វិបត្តិស្បែកនិងជាលិកាទន់៖ ឡើងកន្ទួលរមាស់ ក្រហមស្បែកកន្ទាលត្រអាក
-វិបត្តិថ្លើមនិងប្រម៉ាត់៖ កើនឡើងអង់ហ្ស៊ីមក្នុងថ្លើមកើនឡើងកំរិត ប៊ីលីរុយប៊ីនក្នុងថ្លើម
-វិបត្តិឆ្អឹងសាច់ដុំ៖ ឈឺឆ្អឹងសាច់ដុំ ឈឺសន្លាក់
-វិបត្តិតំរងនោម៖ ខ្សោយតំរងនោម
-វិបត្តិទូទៅនិងលើកន្លែងប្រើ៖ អស់កម្លាំង ក្តៅខ្លួន

➢ ត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យប្រសិនបើមានប្រតិកម្មរំខានណាមួយកើតឡើង។

### VII អន្តរកម្មឱសថ :
គួរជៀសវាងប្រើរួមគ្នាជាមួយឱសថដូចខាងក្រោម៖
-Tizanidine, Methotrexate, Theophylline
-Xanthine derivatives, Caffeine, Pentoxifylline
-Phenytoin, Cyclosporine
-Vitamin K antagonist
-Glibenclamide, Ropidirole
-Lidocaine, Clozapine
-Sildenafil

### VIII ការរក្សាទុក :
-ត្រូវរក្សាទុកនៅសីតុណ្ហភាពក្រោម៣០°C
-ត្រូវទុកកុំឲ្យត្រូវកំដៅថ្ងៃ និងសំណើម
-ត្រូវទុកឲ្យផុតពីដៃកូនក្មេង

### IX កំរិត និងរបៀបប្រើ :

❖ **កំរិតប្រើ៖**

**ចំពោះមនុស្សពេញវ័យ៖**

-សំរាប់ព្យាបាលជំងឺឆ្លងក្នុងផ្លូវដង្ហើមផ្នែកខាងក្រោម៖ កំរិតប្រើគឺ 400mg ប្រើ ២ដង ក្នុង១ថ្ងៃ ទៅ 400mg ប្រើ៣ដង ក្នុង១ថ្ងៃ។រយៈពេលព្យាបាលសរុបគឺពី៧ទៅ១៤ថ្ងៃ។
-សំរាប់ព្យាបាលជំងឺឆ្លងក្នុងផ្លូវដង្ហើមផ្នែកខាងលើ៖
- ជំងឺរលាកឆ្អឹងរូងច្រមុះស្រួចស្រាវនិងរ៉ាំរ៉ៃ៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ ទៅ 400mg ប្រើ៣ដងក្នុង១ថ្ងៃ។ រយៈពេលព្យាបាលសរុប គឺពី៧ទៅ១៤ថ្ងៃ។
- ជំងឺអំបៅអំបែកត្រចៀករ៉ាំរ៉ៃ៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ ទៅ 400mg ប្រើ៣ដង ក្នុង១ថ្ងៃ។ រយៈពេលព្យាបាលសរុបគឺពី៧ទៅ១៤ថ្ងៃ។
- ជំងឺអំបៅអំបែកត្រចៀកកាចសាហាវ៖ កំរិតប្រើគឺ 400mg ប្រើ៣ដងក្នុង១ថ្ងៃ។រយៈពេលព្យាបាលសរុប គឺពី២៨ថ្ងៃទៅ៣ខែ។

-សំរាប់ព្យាបាលជំងឺរលាកផ្លោកនោមកំរិតស្រាលនិងកំរិតធ្ងន់៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ ទៅ 400mg ប្រើ៣ដង ក្នុង១ថ្ងៃ។ រយៈពេលព្យាបាលសរុបគឺពី៧ទៅ២១ថ្ងៃ។រយៈពេលប្រើឱសថនេះអាចអូសបន្លាយលើសពី២១ថ្ងៃ ក្នុងលក្ខខណ្ឌមួយចំនួន (ករណីមានដំបៅអាប់សែ)។
-សំរាប់ព្យាបាលជំងឺរលាកក្រពេញប្រូស្តាត៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃទៅ 400mg ប្រើ៣ដង ក្នុង១ថ្ងៃ។ រយៈពេលព្យាបាលសរុបគឺពី២ទៅ៤សប្តាហ៍ (ករណីស្រួចស្រាវ)។
-សំរាប់ព្យាបាលជំងឺរលាកឆ្អឹងត្រគាកនិងជំងឺឆ្លងក្នុងផ្លោកនោម៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ ទៅ 400mg ប្រើ៣ដង ក្នុង១ថ្ងៃ។រយៈពេលព្យាបាលសរុបគឺតិចជាង១៤ថ្ងៃ។
-សំរាប់ព្យាបាលជំងឺឆ្លងក្នុងក្រពះពោះវៀន៖
- ជំងឺរាកដោយសារមេរោគ Shigella spp.៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ។ រយៈពេលព្យាបាលសរុបគឺ ១ថ្ងៃ។
- ជំងឺរាកដោយសារមេរោគ Shigella dysenteriae type 1៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ។ រយៈពេលព្យាបាល សរុបគឺ ៥ថ្ងៃ។
- ជំងឺរាកដោយសារមេរោគ Vibrio cholera៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ។ រយៈពេលព្យាបាលសរុបគឺ ៣ថ្ងៃ។
- ជំងឺគ្រុនពោះវៀន៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ។ រយៈពេលព្យាបាលសរុបគឺ ៧ថ្ងៃ។

-សំរាប់ព្យាបាលជំងឺឆ្លងផ្ទៃខាងក្នុងពោះ៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ ទៅ 400mg ប្រើ៣ដង ក្នុង១ថ្ងៃ។ រយៈពេលព្យាបាលសរុបគឺពី៥ទៅ១៤ថ្ងៃ។
-ជំងឺឆ្លងលើស្បែកនិងជាលិកាទន់៖ កំរិតប្រើគឺ 400mg ប្រើ២ដងក្នុង១ថ្ងៃ ទៅ 400mg ប្រើ៣ដង ក្នុង១ថ្ងៃ។ រយៈពេលព្យាបាលសរុបគឺពី៧ទៅ១៤ថ្ងៃ។
-ជំងឺឆ្លងក្នុងសន្លាក់និងឆ្អឹង៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ ទៅ 400mg ប្រើ៣ដង ក្នុង១ថ្ងៃ។ រយៈពេលព្យាបាលសរុបគឺ៣ខែ។
-សំរាប់គ្រប់គ្រងការកើនឡើងចំនួន neutrophils ចំពោះអ្នកជំងឺគ្រុនក្តៅដែល សង្ស័យថាមានជំងឺឆ្លង៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ ទៅ 400mg ប្រើ៣ដង ក្នុង១ថ្ងៃ។រយៈពេលព្យាបាលសរុបគឺត្រូវបន្តធ្វើ រហូតទាល់តែចំនួន neutrophils វិលមករកសភាពធម្មតាវិញ។
-សំរាប់ព្យាបាលនិងបង្ការកាពុលដោយសារសារធាតុ anthrax៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ។ រយៈពេលព្យាបាលសរុបគឺ៦០ថ្ងៃ។ការព្យាបាលត្រូវធ្វើភ្លាមៗក្រោយពេលសង្ស័យថាមានការប៉ះពាល់ជាមួយនឹង សារធាតុពុលនេះ។

**ចំពោះកូនក្មេង និងមនុស្សវ័យជំទង់៖**

-សំរាប់ព្យាបាលជំងឺតំណពូជឆ្លងក្នុងសួត៖ កំរិតប្រើគឺ 10mg ក្នុងទម្ងន់ខ្លួន 1kg ចែកជា៣ដង ក្នុង១ថ្ងៃ។ កំរិតប្រើអតិបរិមាគឺ 400mg ក្នុងពេលប្រើ១ដង។ រយៈពេលព្យាបាលសរុបគឺពី១០ទៅ១៤ថ្ងៃ។
-សំរាប់ព្យាបាលជំងឺឆ្លងក្នុងផ្លូវតំរងនោមនិងរលាកផ្លោកនោម៖ កំរិតប្រើគឺពី 6mg ក្នុងទម្ងន់ខ្លួន 1kg ប្រើ៣ដងក្នុង១ថ្ងៃ ទៅ 10mg ក្នុងទម្ងន់ខ្លួន 1kg ប្រើ៣ដងក្នុង១ថ្ងៃ។ កំរិតប្រើអតិបរិមាគឺ 400mg ក្នុងពេលប្រើ១ដង។ រយៈពេលព្យាបាលសរុបគឺពី១០ទៅ២១ថ្ងៃ។
-សំរាប់ព្យាបាលនិងបង្ការកាពុលដោយសារសារធាតុ anthrax៖ កំរិតប្រើគឺពី 10mg ក្នុងទម្ងន់ខ្លួន 1kg ប្រើ២ដងក្នុង១ថ្ងៃ ទៅ 15mg ក្នុងទម្ងន់ខ្លួន 1kg ប្រើ២ដងក្នុង១ថ្ងៃ។ កំរិតប្រើអតិបរិមាគឺ 400mg ក្នុងពេលប្រើ១ដង។ រយៈពេលព្យាបាលសរុបគឺ៦០ថ្ងៃ។ ការព្យាបាលត្រូវធ្វើភ្លាមៗក្រោយពេលសង្ស័យថាមានការប៉ះពាល់ជាមួយនឹង សារធាតុពុលនេះ។
-សំរាប់ព្យាបាលជំងឺឆ្លងធ្ងន់ធ្ងរផ្សេងទៀត៖ កំរិតប្រើគឺពី 10mg ក្នុងទម្ងន់ខ្លួន 1kg ប្រើ៣ដងក្នុង១ថ្ងៃ។ កំរិតប្រើអតិបរិមាគឺ 400mg ក្នុងពេលប្រើ១ដង។ រយៈពេលព្យាបាលសរុបគឺអាស្រ័យទៅតាមប្រភេទជំងឺឆ្លង។

**ចំពោះមនុស្សចាស់៖**

-កំរិតប្រើគឺអាស្រ័យទៅតាមប្រភេទជំងឺឆ្លងនិងកំរិត creatinine របស់អ្នកជំងឺ។

**ចំពោះអ្នកជំងឺខ្សោយមុខងារតំរងនោម៖** កំរិតប្រើឱសថនេះ គឺអាស្រ័យទៅតាមកំរិត creatinine ក្នុងឈាមរបស់អ្នកជំងឺដូចខាងក្រោម៖
-កាលណាកំរិត creatinine ធំជាង 60ml/min៖ កំរិតប្រើគឺប្រើកំរិតធម្មតា។
-កាលណាកំរិត creatinine នៅចន្លោះពី 30ml/min ទៅ 60ml/min៖ កំរិតប្រើគឺ 200mg ទៅ 400mg រៀងរាល់១២ម៉ោងម្តង។
-កាលណាកំរិត creatinine តូចជាង 30ml/min៖ កំរិតប្រើគឺ 200mg ទៅ 400mg រៀងរាល់២៤ម៉ោងម្តង។
-ករណីលាងឈាម៖ កំរិតប្រើគឺ 200mg ទៅ 400mg រៀងរាល់២៤ម៉ោងម្តង (ក្រោយពេលលាងឈាមរួច)។

❖ **ការណែនាំពីរបៀបប្រើ៖**

-ឱសថនេះប្រើចាក់ព្យួរតាមសរសៃឈាមតែប៉ុណ្ណោះ។
-សំរាប់កូនក្មេង៖ ត្រូវប្រើរយៈពេលព្យួរតាមសរសៃឈាម៦០នាទី។
-សំរាប់មនុស្សពេញវ័យ៖ ចំពោះកំរិតប្រើ 400mg ត្រូវប្រើរយៈពេលព្យួរតាម សរសៃឈាម៦០នាទី និងចំពោះកំរិតប្រើ 200mg ត្រូវប្រើរយៈពេលព្យួរតាម សរសៃឈាម៣០នាទី។
-ត្រូវបង្ហូរថ្នាំនេះយឺតៗតាមសរសៃវ៉ែនធំដើម្បីជៀសវាងការរលាកសរសៃឈាម។

➢ មុននឹងប្រើឱសថនេះ ត្រូវពិគ្រោះជាមួយគ្រូពេទ្យ។

### X លេខបញ្ជិកា : CAM N0085IP-17

### XI ផលិតដោយ : Abaris Healthcare Pvt. Ltd. (India)
បានបកប្រែនិងត្រួតពិនិត្យដោយនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង។
លេខ:១៧៤៥/១៧ឱអបស ចុះថ្ងៃទី០៥ ខែ មិថុនា ឆ្នាំ២០១៧